# សេចក្តីអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក



# សេចក្តីអធិស្ឋាននៅពេលព្រឹក

អរព្រះគុណព្រះយេស៊ូវសម្រាប់ថ្ងៃថ្មី ហើយនិងជីវិតដែលទ្រង់បានប្រទានមកទូលបង្គំ។

កូនសូមអរព្រះគុណប្រាជ្ញាញាណ និងសម្រាប់កម្លាំងដែលទ្រង់បានប្រទានទូលបង្គំ។
សូមដឹកនាំ និងណែនាំអ្វីៗដែលទូលបង្គំនឹងធ្វើ ហើយនិងនិយាយពេញមួយថ្ងៃមួយនេះ។
ព្រះអម្ចាស់អើយ សូមប្រទានពរដល់ក្រុមគ្រួសារទូលបង្គំ។ សូមការពារយើងខ្ញុំ ហើយសូមផ្គត់ផ្គង់អ្វីដែលយើងខ្ញុំត្រូវការសម្រាប់ថ្ងៃនេះ។
សូមឲ្យទូលបង្គំធ្វើអ្វីៗដែលព្រះអង្គគាប់ព្រះហឫទ័យ ហើយសូមឲ្យទូលបង្គំមានចំណែកពង្រីកព្រះរាជ្យទ្រង់នៅថ្ងៃនេះ។
កូនអធិស្ឋានទូលថ្វាយទាំងអស់នេះ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
អាម៉ែន



# សេចក្តីអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក

# សេចក្តីអធិស្ឋានសម្រាប់ការព្យាបាល

អរព្រះគុណព្រះអម្ចាស់យេស៊ូវសម្រាប់ការថែរក្សា និងការព្យាបាលនៅក្នុងជីវិតយើងខ្ញុំ។ កូនដឹងថា ព្រះអង្គជាគ្រូពេទ្យដ៏អស្ចារ្យ ហើយពេញដោយសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណា។ កូនដឹងថា រាលជំងឺ/ការឈឺចាប់មកពីសាតាំង/វិញ្ញាណអាក្រក់។ ថ្ងៃនេះកូនមិនស្រួលខ្លួន (ប្រាប់អ្វីដែលអ្នកឈឺ)។ សូមព្យាបាលទូលបង្គំពីជំងឺផង។

ឬអធិស្ឋានសម្រាប់អ្នកដទៃទៀតៈ
ថ្ងៃនេះ (ប្រាប់ឈ្មោះអ្នកជម្ងឺ) មិនស្រួលខ្លួន (និយាយអ្វីដែលគាត់ឈឺ)។
យើងប្រកាសដោយនៅក្នុងសិទ្ធិអំណាចនៃព្រះនាមព្រះយេស៊ូវ ហើយបញ្ជារាល់ជម្ងឺ/ពិការភាព/ការឈឺចាប់ ចេញនៅពេលនេះ។ យើងស្រាយការព្យាបាលនៅក្នុងរូបរាងកាយរបស់ពួកគេ ដោយនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

យើងជឿថា បង/ប្អូន (ឈ្មោះ...) ថាព្រះអង្គនឹងបង្ហូរព្យាបាលមក ហើយនឹងបានជាទីបន្ទាល់ពីសេចក្តីសប្បុរស និងតេជានុភាពនៃព្រះ ដើម្បីបង្រីកព្រះរាជ្យទ្រង់។
កូនអធិស្ឋានទូលថ្វាយទាំងអស់ ដោយនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
អាម៉ែន



# សេចក្តីអធិស្ឋានសម្រាប់ពេលល្ងាច

អរព្រះគុណព្រះយេស៊ូវដែលព្រះអង្គបានថែរក្សាយើងខ្ញុំឲ្យមានសុវត្ថិភាព ហើយផ្គត់ផ្គង់រាល់តម្រូវការរបស់យើងខ្ញុំ។
កូនអរព្រះគុណសម្រាប់គ្រប់ទាំងកិច្ចការល្អ និងកិច្ចការដែលពិបាកផងដែរ។
សូមឲ្យទូលបង្គំបានគេងលង់លក់ស្កប់ស្កល់ ក្រោម**ការថែរក្សា**នៃព្រះអង្គពេញមួយយប់នេះ។

សូមការពារយើងពីមារកំណាច និងគ្រោះថ្នាក់។
សូមប្រទានសុបិននិមិត្ត ដែលជួយយើងឲ្យកាន់តែស្រឡាញ់ទ្រង់ថែមទៀត ហើយស្គាល់ផែនការណ៍ទ្រង់មានសម្រាប់យើង។

កូនទូលថ្វាយជីវិតទូលបង្គំទៅទ្រង់ ដោយនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
អាម៉ែន



# អរព្រះគុណ

*(សេចក្ដីអធិស្ឋានមុនពេលញ៉ាំអាហារ)*

អរព្រះគុណព្រះយេស៊ូវសម្រាប់ការផ្គត់ផ្គង់ និងសម្រាប់ម្ហូបអាហារនេះ។
យើងថ្វាយព្រះពរសម្រាប់អាហារនេះ ដោយនៅក្នុងព្រះនាមព្រះយេស៊ូវថា វានឹងធ្វើឲ្យយើងមានសុខភាពល្អ ហើយមិនបង្កហានិភ័យដល់យើងសោះឡើយ។
នៅពេលយើងទទួលទានអាហារនេះ សូមឲ្យបានចម្រើនកម្លាំងដល់រាងកាយយើង ប្រយោជន៍ឲ្យយើងបានបម្រើទ្រង់ព្រះអង្គ ហើយព្រះរាជ្យទ្រង់ចម្រើនឡើងថែមទៀត។
សូមឲ្យអស់អ្នកដែលជួយរៀបចំម្ហូបអាហារ ទទួលបានព្រះពរពីទ្រង់ផងដែរ។
កូនអធិស្ឋានដោយនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
**អាម៉ែន**



# សេចក្ដីអធិស្ឋានសម្រាប់ពេលមានបន្ទុក/ បញ្ហាផ្សេងៗ

កូនអរព្រះគុណទ្រង់ព្រះយេស៊ូវ ហើយសូមថ្វាយព្រះទ្រង់កណ្ដាលនៃបន្ទុក/ឧបសគ្គ/បញ្ហា....(និយាយឈ្មោះបញ្ហា)។ កូនជឿថា ព្រះអង្គតែងមានផែនការសម្រាប់យើងខ្ញុំ ដើម្បីជួយយើងលូតលាស់ឡើង និងកាន់តែមានលក្ខណៈ
កាន់តែដូចព្រះយេស៊ូវ។

សូមប្រទានប្រាជ្ញាដល់យើងខ្ញុំ ហើយដឹកនាំយើងខ្ញុំឆ្ពោះទៅដំណោះស្រាយសម្រាប់បញ្ហានេះ ស្របតាមព្រះហឫទ័យទ្រង់។ កូនដាក់សេចក្ដីទុកចិត្តរបស់នៅក្នុងព្រះអម្ចាស់ ហើយកូននឹងមិនខ្វល់ខ្វាយ ឬបារម្ភទៀតឡើយ ពីព្រោះទូលបង្គំដឹងថា ព្រះអង្គតែឆ្លើយតបទាន់ពេល។

សូមឲ្យ**ចម្លើយ** ចំពោះ**សេចក្ដីអធិស្ឋាន**នេះជួយយើងខ្ញុំកាន់តែទុកចិត្តដល់ព្រះអង្គថែមទៀត ហើយជួយអ្នកផ្សេងទៀតឲ្យឃើញពីសេចក្ដីស្រឡាញ់ទ្រង់ និងគេជនុភាពរបស់ព្រះអង្គ ប្រយោជន៍ឲ្យរាជ្យទ្រង់បានចម្រើនឡើង។
កូនអធិស្ឋានដោយនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
**អាម៉ែ**

